# II- ឯកសារគណៈរដ្ឋមន្ត្រី

## ១-អនុក្រឹត្យ

រាជធានីភ្នំពេញ,ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៩៥

**អនុក្រឹត្យលេខ ៦៧ អនក្រ.បក**

**ស្តីពី**

**ការបង្កើតគណៈកម្មាធិការទំនាក់ទំនងព្រំដែនកម្ពុជា_ថៃ**

* * *

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ១៤ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតក្រសួងការពារជាតិ និង អគ្គសេនាធិការ នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ២៩ អនក្រ. ចុះថ្ងៃទី ២ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតគណៈកម្មការទំនាក់ទំនងការងារជាមួយកងយោធពលភូមិន្ទថៃ
- បានឃើញសេចក្តីសំរេចលេខ ១៧ សសរ. ចុះថ្ងៃទី ៨ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតគណៈកម្មការចំរុះ សំរាប់កិច្ចសហប្រតិបត្តិការ ខ្មែរ_ថៃ
- ដើម្បីបង្កើនទំនាក់ទំនងការងារជាមួយកងយោធពលភូមិន្ទថៃ សំដៅការពារសន្តិសុខ ជានាសុវត្ថិភាពនៅតាមព្រំដែនកម្ពុជា_ថៃ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

**សំរេច**

**មាត្រា ១:** គណៈកម្មការទំនាក់ទំនងការងារជាមួយកងយោធពលភូមិន្ទថៃ ដែលបានបង្កើតឡើងតាម អនុក្រឹត្យលេខ ២៩ អនក្រ. ចុះថ្ងៃទី ២ កុម្ភៈ ឆ្នាំ ១៩៩៥ ត្រូវបានហៅថា

"គណៈកម្មាធិការទំនាក់ទំនងព្រំដែន កម្ពុជា_ថៃ" ចំណុះការដឹកនាំផ្ទាល់របស់សម្តេចនាយករដ្ឋមន្ត្រីទី ១ និងសម្តេចនាយករដ្ឋមន្ត្រីទី ២ និងជាសហអគ្គមេបញ្ជាការកងយោធពល ខេមរភូមិន្ទ ហើយត្រូវបានកែសម្រួលសមាសភាព ដូចខាងក្រោម ÷

១_សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ជាប្រធាន

២_នាយអគ្គសេនាធិការ ជាអនុប្រធាន

៣_នាយរងអគ្គសេនាធិការ ជាសមាជិក

៤_រដ្ឋលេខាធិការក្រសួងការពារជាតិ ជាសមាជិក

៥_រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ជាសមាជិក

៦_តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិក

៧_រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាសមាជិក

៨_អនុរដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជាសមាជិក

៩_ឯកអគ្គរាជទូតកម្ពុជា ប្រចាំក្រុងបាងកក ជាសមាជិក

១០_មេបញ្ជាការកងនាវាចរខេមរភូមិន្ទ ជាសមាជិក

១១_មេបញ្ជាការកងអាកាសចរខេមរភូមិន្ទ ជាសមាជិក

១២_នាយកទីចាត់ការគលយុទ្ធ អគ្គបញ្ជាការដ្ឋាន ជាសមាជិក

១៣_នាយកខុទ្ទកាល័យយោធាក្រសួងការពារជាតិ ជាសមាជិក

១៤_នាយកខុទ្ទកាល័យស៊ីវិលក្រសួងការពារជាតិ ជាសមាជិក

១៥_នាយកនាយកដ្ឋានឃោសនាសាធារណៈក្រសួងការពារជាតិ ជាសមាជិក

១៦_មេបញ្ជាការកងការពារព្រំដែន ជាសមាជិក និងលេខាធិការ

១៧_នាយកនាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេសក្រសួងពាណិជ្ជកម្ម ជាសមាជិកនិងលេខាធិការរង

**មាត្រា ២ :** បង្កើតគណៈកម្មាធិការ រក្សាសន្តិភាពព្រំដែនទូទៅ សំរាប់ដោះស្រាយការងារប្រចាំថ្ងៃដែល រួមមានសមាសភាពដូចខាងក្រោម ÷

១_នាយអគ្គសេនាធិការ នៃកងយោធពលខេមរភូមិន្ទ ជាប្រធាន

២_នាយរងអគ្គសេនាធិការ ជាអនុប្រធាន

៣_រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ ជាអនុប្រធាន

៤_អនុរដ្ឋលេខាធិការ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជាអនុប្រធាន

| | |
|---|---|
| ៥_អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | ជាសមាជិក |
| ៦_តំណាងទីស្ដីការគណៈរដ្ឋមន្ត្រី | ជាសមាជិក |
| ៧_តំណាងអាជ្ញាធរជាតិកម្ពុជា ទទួលបន្ទុកការងារព្រំដែន | ជាសមាជិក |
| ៨_ឯកអគ្គរាជទូតកម្ពុជា ប្រចាំក្រុងបាងកក | ជាសមាជិក |
| ៩_អគ្គនាយករងនគរបាលជាតិ | ជាសមាជិក |
| ១០_នាយក នាយកដ្ឋានស្រាវជ្រាវ និង ចារកិច្ច អគ្គបញ្ជាការដ្ឋាន | ជាសមាជិក |
| ១១_មេបញ្ជាការកងការពារព្រំដែន | ជាសមាជិក |
| ១២_មេបញ្ជាការរង កងនាវាចរខេមរភូមិន្ទ | ជាសមាជិក |
| ១៣_មេបញ្ជាការរង កងអាកាសចរខេមរភូមិន្ទ | ជាសមាជិក |
| ១៤_នាយការិយាល័យទី ៣ អគ្គសេនាធិការ | ជាសមាជិក |
| ១៥_នាយក ទីចាត់ការគយ និង រដ្ឋាករ | ជាសមាជិក |
| ១៦_ប្រធាននាយកដ្ឋាន រុក្ខា-ប្រមាញ់ | ជាសមាជិក |
| ១៧_ប្រធាននាយកដ្ឋានកណ្ដាលនគរបាលព្រំដែន ក្រសួងមហាផ្ទៃ | ជាសមាជិក |
| ១៨_នាយក នាយកដ្ឋានទាក់ទងអន្តរជាតិ ក្រសួងការពារជាតិ | ជាសមាជិក |
| ១៩_ប្រធានការិយាល័យប្រឆាំងគ្រឿងញៀន ក្រសួងមហាផ្ទៃ | ជាសមាជិក |
| ២០_មេបញ្ជាការរងកងការពារព្រំដែន | ជាសមាជិកនិងលេខាធិការ |
| ២១_នាយការិយាល័យទី ៣ កងនាវាចរខេមរភូមិន្ទ | ជាសមាជិកនិងលេខាធិការរង |

**មាត្រា ៣** : បង្កើតគណៈកម្មាធិការថ្នាក់យោធភូមិភាគ សំរាប់ដោះស្រាយការងារតាមមូលដ្ឋានរបស់ខ្លួន ដែលរួមមានសមាសភាពដូចខាងក្រោម ÷

**យោធភូមិភាគទី ៤**

| | |
|---|---|
| ១_មេបញ្ជាការយោធភូមិភាគ ៤ | ជាប្រធាន |
| ២_មេបញ្ជាការរងយោធភូមិភាគ ៤ | ជាអនុប្រធាន |
| ៣_អភិបាលខេត្ត ព្រះវិហារ | ជាអនុប្រធាន |
| ៤_អភិបាលខេត្ត ឧត្ដរមានជ័យ | ជាអនុប្រធាន |
| ៥_អភិបាលខេត្ត សៀមរាប | ជាអនុប្រធាន |
| ៦_មេបញ្ជាការកងពលធំលេខ ៣ | ជាសមាជិក |
| ៧_មេបញ្ជាការកងពលធំលេខ ១៤ | ជាសមាជិក |

៨_តំណាងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជាសមាជិក
៩_នគរបាលអន្តោប្រវេសន៍ខេត្តព្រះវិហារ, ឧត្តរមានជ័យ, សៀមរាប ជាសមាជិក
១០_ទីស្នាក់ការគយនិងរដ្ឋាករ ខេត្តព្រះវិហារ, ឧត្តរមានជ័យ, សៀមរាប ជាសមាជិក
១១_ចៅក្រសួងពាណិជ្ជកម្មខេត្តព្រះវិហារ, ឧត្តរមានជ័យ, សៀមរាប ជាសមាជិក
១២_ចៅក្រសួងកសិកម្ម ខេត្តព្រះវិហារ , ឧត្តរមានជ័យ , សៀមរាប ជាសមាជិក
១៣_នាយសេនាធិការ យោធភូមិភាគទី ៤ ជាសមាជិកនិងលេខាធិការ
១៤_នាយសេនាធិការកងពលធំលេខ ៣ ជាសមាជិកនិងលេខាធិការរង
១៥_នាយសេនាធិការកងពលធំលេខ ១៤ ជាសមាជិកនិងលេខាធិការរង

**យោធភូមិភាគទី ៥**

១_មេបញ្ជាការយោធភូមិភាគទី ៥ ជាប្រធាន
២_មេបញ្ជាការរងយោធភូមិភាគទី ៥ ជាអនុប្រធាន
៣_អភិបាលខេត្តបន្ទាយមានជ័យ ជាអនុប្រធាន
៤_អភិបាលខេត្តបាត់ដំបង ជាអនុប្រធាន
៥_មេបញ្ជាការកងពលធំលេខ ១២ ជាសមាជិក
៦_មេបញ្ជាការកងពលធំលេខ ៧ ជាសមាជិក
៧_នគរបាលអន្តោប្រវេសន៍ ខេត្តបន្ទាយមានជ័យ, បាត់ដំបង ជាសមាជិក
៨_តំណាងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជាសមាជិក
៩_ចៅក្រសួងពាណិជ្ជកម្ម ខេត្តបន្ទាយមានជ័យ , បាត់ដំបង ជាសមាជិក
១០_ចៅក្រសួងកសិកម្ម ខេត្តបន្ទាយមានជ័យ , បាត់ដំបង ជាសមាជិក
១១_ទីស្នាក់ការ គយ និងរដ្ឋាករ ខេត្តបន្ទាយមានជ័យ , បាត់ដំបង ជាសមាជិក
១២_នាយសេនាធិការ យោធភូមិភាគទី ៥ ជាសមាជិកនិងលេខាធិការ
១៣_នាយសេនាធិការ កងពលធំលេខ ១២ ជាសមាជិកនិងលេខាធិការរង
១៤_នាយសេនាធិការ កងពលធំលេខ ៧ ជាសមាជិកនិងលេខាធិការរង

**យោធភូមិភាគទី ៣**

១_មេបញ្ជាការយោធភូមិភាគទី ៣ ជាប្រធាន
២_មេបញ្ជាការរងយោធភូមិភាគទី ៣ ជាអនុប្រធាន
៣_អភិបាលខេត្តកោះកុង ជាអនុប្រធាន

៤_មេបញ្ជាការកងនាវាចរខេមរភូមិន្ទ (មូលដ្ឋានសមុទ្រ) ជាអនុប្រធាន
៥_មេបញ្ជាការតំបន់ប្រតិបត្តិការសឹករង ខេត្តកោះកុង ជាអនុប្រធាន
៦_តំណាងក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ជាសមាជិក
៧_ទីស្នាក់ការគយ និង រដ្ឋាករ ខេត្តកោះកុង ជាសមាជិក
៨_ចៅក្រសួងពាណិជ្ជកម្ម ខេត្តកោះកុង ជាសមាជិក
៩_ចៅក្រសួងកសិកម្ម ខេត្តកោះកុង ជាសមាជិក
១០_នគរបាលអន្តោប្រវេសន៍ ខេត្តកោះកុង ជាសមាជិក
១១_មេបញ្ជាការកងវរសេនាតូច ការពារព្រំដែនខេត្តកោះកុង ជាសមាជិក
១២_មេបញ្ជាការកងវរសេនាតូច នាវាចរល្បាតព្រំដែនសមុទ្រ ជាសមាជិក
១៣_នាយសេនាធិការយោធភូមិភាគទី ៣ ជាសមាជិក
១៤_នាយការិយាល័យទី ៣ យោធភូមិភាគទី ៣ ជាសមាជិក និង លេខាធិការ
១៥_នាយសេនាធិការកងនាវាចរមូលដ្ឋានសមុទ្រ ជាសមាជិក និងលេខាធិការរង
១៦_មេបញ្ជាការរងតំបន់ប្រតិបត្តិការសឹករងខេត្តកោះកុង ជាសមាជិកនិងលេខាធិការរង

**មាត្រា ៤ :** ដើម្បីជាជំនួយដល់គណៈកម្មាធិការនេះ ក្នុងការសហការដោះស្រាយការងារអោយបានល្អ ទៅតាមភូមិសាស្ត្រនីមួយៗ ចាំបាច់ត្រូវរៀបចំការិយាល័យ និងក្រុមការងារមួយចំនួនប្រចាំតាមបណ្តាទិសនៃយោធភូមិភាគនីមួយៗ ។ ចំពោះសមាសភាព និងភារកិច្ចរបស់ការិយាល័យ និងក្រុមការងារនីមួយៗ អាស្រ័យដោយគណៈកម្មាធិការព្រំដែនទូទៅ និង គណៈកម្មាធិការរក្សាសន្តិភាពព្រំដែនទូទៅជាអ្នករៀបចំ និងកំណត់ជាក់ស្តែង ។

**មាត្រា៥ :** គណៈកម្មាធិការនេះ មានភារកិច្ចរិះរកវិធានការដឹកនាំដ៏សមស្របដើម្បីលើកស្ទួយសហប្រតិបត្តិការ រក្សាសន្តិភាពតាមបណ្តោយព្រំដែន នៃប្រទេសទាំងពីរកម្ពុជា-ថៃ ។ ចេញបទបញ្ជា គោលនយោបាយ និង ផែនការអោយគណៈកម្មាធិការភូមិភាគ ការិយាល័យ និង ក្រុមការងារ ដើម្បីអនុវត្តអោយបានល្អប្រសើរនូវរាល់ទំនាក់ទំនងនេះ ។ ចាត់តាំងគណៈកម្មាធិការឯកទេស ដើម្បីដោះស្រាយរាល់ករណីដែលកើតក្នុងក្របខ័ណ្ឌគណៈកម្មាធិការនីមួយៗ ។

**មាត្រា ៦** : ទីកន្លែងធ្វើការរបស់គណៈកម្មាធិការព្រំដែនទូទៅនៅក្រសួងការពារជាតិ ។ ចំណែកឯគណៈកម្មាធិការរក្សាសន្តិភាពព្រំដែនទូទៅ ធ្វើការនៅទីបញ្ជាការដ្ឋានកងការពារព្រំដែនអគ្គសេនាធិការ ។

**មាត្រា ៧** : គណៈកម្មាធិការព្រំដែនទូទៅ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងការពារជាតិ ។ ចំពោះគណៈកម្មាធិការរក្សាសន្តិភាពព្រំដែនទូទៅ មានសិទ្ធិប្រើប្រាស់ត្រារបស់អគ្គសេនាធិការ ។

**មាត្រា ៨** : ចាត់ទុកជានិរាករណ៍នូវអនុក្រឹត្យលេខ ២៩ អនក្រ. ចុះថ្ងៃទី ២ ខែកុម្ភៈឆ្នាំ ១៩៩៥ ។

**មាត្រា ៩** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រី ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ នាយអគ្គសេនាធិការកងយោធពលខេមរភូមិន្ទ អគ្គនាយកនគរបាលជាតិ ស្ថាប័នពាក់ព័ន្ធនិងសមាសភាពស្ថិតនៅក្នុង មាត្រា ១ , មាត្រា ២ , មាត្រា ៣ , ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ។

**មាត្រា ១០**: អនុក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានិងចុះហត្ថលេខាតទៅ ។

**នាយករដ្ឋមន្ត្រីទី ១** **នាយករដ្ឋមន្ត្រីទី ២**

**ព្រះហស្តលេខា និងត្រា** **ហត្ថលេខា និង ត្រា**

**នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ១៩៩៥

## អនុក្រឹត្យ លេខ ៦៨ អនក្រ.បក

## ស្តីពីការបង្កើតមន្ទីរប្រឆាំងគ្រឿងញៀន

* * *

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន**